**វេទិកាថ្នាក់ជាតិនៃគំនិតផ្តួចផ្តើមថ្មីតាមមូលដ្ឋានលើប្រធានបទ "តើកសិករអាចក្លាយជាអ្នកច្នៃប្រឌិត រុករកនូវគំនិតថ្មីបានដែរឬទេ? "**

វេទិកាថ្នាក់ជាតិនេះត្រូវបានប្រព្រឹត្តិទៅនៅសណ្ឋាគារជូលីណា នាទីក្រុងភ្នំពេញ នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួមសរុប ១៣៦ នាក់ ស្ត្រី ៣០ នាក់ មកពីខេត្តចំនួន ១១ ក្នុងនោះមានស្ថាប័នចំនួន ២៦ ចូលរួម គឺមន្ទីរកសិកម្មចំនួន ៩ (តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង បាត់ដំបង កំពង់ធំ ពោធិ៍សាត់ កំពង់ចាម)។ នាយកដ្ឋានចំនួន ២ (នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម) អង្គការមិនមែនរដ្ឋាភិបាលចំនួន ១០ ស្ថាប័នអប់រំចំនួន ៣ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម សាលាជាតិកសិកម្មព្រែកលៀប) បណ្តាញកសិករ និងធម្មជាតិ ព្រមទាំងក្រុមប្រឹក្សាឃុំធ្លក ខេត្តតាកែវ។

គោលបំណងសំខាន់នៃអង្គវេទិកានេះគឺ:

- ដើម្បីធ្វើការគាំទ្រ និងជំរុញនូវគំនិតផ្តួចផ្តើមរបស់កសិករក្នុងការស្រាវជ្រាវរុករកនូវគំនិតថ្មី
- ឱ្យអ្នកស្រាវជ្រាវ អ្នកផ្សព្វផ្សាយ កសិករ និងអ្នកពាក់ព័ន្ធផ្សេងទៀតមានឱកាសបានជួបជុំគ្នា ដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធន៍នូវគំនិតថ្មីរបស់ពួកគាត់ឱ្យគ្នាទៅវិញទៅមក

ជាលទ្ធផលយើងសង្កេតឃើញថា

- ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** មានការចាប់អារម្មណ៍ និងគាំទ្រយ៉ាងខ្លាំងចំពោះវេទិកាដែលបានរៀបចំនេះ ហើយឯកឧត្តមនឹងបង្កើតឱ្យមានជាមូលនិធិថ្នាក់ជាតិ ដើម្បីធ្វើការគាំទ្រទៅលើការស្រាវជ្រាវរុករកនូវគំនិតថ្មីដោយកសិករ តាមសំណូមពររបស់ បណ្ឌិត **យ៉ង សាំងកុមារ**
- កសិករបានធ្វើការបង្ហាញនូវគំនិតថ្មី ក៏ដូចជាការផ្លាស់ប្តូរនូវជីវភាពរបស់ពួកគាត់ដល់អ្នកចូលរួម តាមរយៈការតាំងពិពណ៌នូវគំនិតថ្មីរបស់គាត់ដោយប្រើប្រាស់ជារូបភាព និងសម្ភារៈផ្សេងៗដែលគាត់បានរៀបចំដោយមានការគាំទ្រពីស្ថាប័នដែលអញ្ជើញគាត់មកចូលរួម
- នៅក្នុងចំណោមកសិករចំនួន ៣២ នាក់ ដែលបានដាក់តាំងបង្ហាញ យើងជ្រើសរើសបានកសិករចំនួន ៥ នាក់ ដែលបានរកឃើញនៅនូវគំនិតថ្មី ហើយមានការចាប់អារម្មណ៍ជាងគេពីសំណាក់អ្នកចូលរួម ដែលក្នុងនោះកសិករ
    - ជាប់ចំណាត់ថ្នាក់លេខ ១ ឈ្មោះ **ទីវ ឆាត** ភេទស្រី ផ្តោតទៅលើប្រធានបទ "បទពិសោធន៍ដាំបន្លែតាមគោលការណ៍ធម្មជាតិនៅលើរាន"
    - ជាប់ចំណាត់ថ្នាក់លេខ ២ ឈ្មោះ **សុខ មុំ** ភេទប្រុស ផ្តោតទៅលើប្រធានបទ "ការផ្សំមេចំណីផ្អាប់សម្រាប់មាន់ និងទឹកខ្ទិសម្រាប់ធ្វើជាវ៉ាក់សាំងការពារជម្ងឺមាន់"

- ជាប់ចំណាត់ថ្នាក់លេខ ៣ ឈ្មោះ **រស់ ម៉ៅ** ភេទប្រុស ក្រោមប្រធានបទ "ឧបករណ៍កែច្នៃក្នុងការស្ទូងជាជួរសម្រាប់ស្រូវ ប.វ.ស"
- ជាប់ចំណាត់ថ្នាក់លេខ ៤ ឈ្មោះ **ជុំ រី** ភេទប្រុស ក្រោមប្រធានបទ " បទពិសោធន៍ក្នុងការចិញ្ចឹមឃ្មុំ"
- ជាប់ចំណាត់ថ្នាក់លេខ ៥ ឈ្មោះ **អ៊ិត ភារុណ** ភេទប្រុស ក្រោមប្រធានបទ " ថ្នាំផ្សំពីរុក្ខជាតិការពារជម្ងឺដង្កោកាច់នៅលើមាន់ និងទា"